YUNNAN DAILY PRESS GROUP
No.196

ប្រទេសចិន-ខេត្តយូនណាន

ភ្ញៀវជាតិ និងអន្តរជាតិផ្ញាស់ប្តូរបទពិសោធន៍អំពីការអភិវឌ្ឍន៍ ដោយចីរភាពនៃពិភពលោក

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8037 ថ្ងៃសុក្រ ទី18 ខែកញ្ញា ឆ្នាំ2019

ហេតុអ្វីបានជាវេទិកាស្តីពីការអភិវឌ្ឍន៍ដោយចីរភាព "Fortune Magazine" ត្រូវរៀបចំនៅខេត្តយូនណាន?

កាលពីថ្ងៃទី៤ ដល់ទី៦ ខែកញ្ញា ឆ្នាំ២០១៩ វេទិកាស្តីពីការអភិវឌ្ឍន៍ដោយចីរភាព"Fortune Magazine"ប្រចាំឆ្នាំ២០១៩ បានរៀបចំនៅក្រុងយូស៊ី នៃខេត្តយូនណានក្រោមប្រធានបទ "អភិវឌ្ឍន៍ដោយបៃតងចែករំលែកគ្នាអំពីអនាគត" ។

ភ្ញៀវជាតិនិងអន្តរជាតិបានផ្ញាស់ប្តូរទស្សនៈ និងពិគ្រោះពិភាក្សាគ្នាអំពីថាមពលបៃតង ការច្នៃប្រឌិតផ្នែកកសិកម្ម ជីវចម្រុះនិងការអភិវឌ្ឍន៍ដោយបៃតង និងការរៀបចំសំរាមជាដើម ហើយបានទទួលលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ។

"Fortune Magazine"ជាទស្សនាវដ្តីល្បីឈ្មោះជាងគេមួយលើពិភពលោក ។ ហេតុអ្វីបាន"Fortune Magazine"រៀបចំវេទិកាស្តីពីការអភិវឌ្ឍន៍ដោយចីរភាពនៅខេត្តយូនណាន ? លោក មូ ឃួយឡាន នាយកប្រតិបត្តិនៃ"Fortune Magazine"បានគូសបញ្ជាក់ថា ខេត្តយូនណានមានអេកូបរិស្ថានយ៉ាងល្អប្រសើរ ហើយសម្បូរទៅដោយធនធានធម្មជាតិ និងមានឧត្តមភាពលើវិស័យទីតាំងភូមិសាស្ត្រ ។ ខេត្តយូនណានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ដោយចីរភាពនៃពិភពលោក ។ ប៉ុន្មានឆ្នាំមកនេះ ខេត្តយូនណានបានផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍ដោយចីរភាព ហើយបានទទួលលទ្ធផលជាក់ស្តែងច្រើនគួរឱ្យកត់សម្គាល់ ។ ដូច្នេះវេទិកាស្តីពីការអភិវឌ្ឍន៍ដោយចីរភាពនៃពិភពលោក ។

"Fortune Magazine"លើកទី ១ បានត្រូវរៀបចំនៅខេត្តយូនណាន ។ ជាការពិតណាស់ថា ជម្រើសនេះពិតជាត្រឹមត្រូវណាស់ ។ ក្នុងឱកាសវេទិកានេះ អ្នកជំនាញការកំពូលលើពិភពលោកបានចូលរួមការផ្ញាស់ប្តូរគ្នាយ៉ាងស៊ីជម្រៅ ហើយបានជំរុញឱ្យសាធារណជនកាន់តែយកចិត្តទុកដាក់ដល់ការអភិវឌ្ឍន៍ដោយចីរភាព ។ ទន្ទឹមនឹងនេះដែរ វេទិកានេះក៏បានបង្ហាញឱ្យឃើញពីសក្តានុពលនៃខេត្តយូនណានក្នុងការអភិវឌ្ឍន៍ដោយចីរភាព ។

តាមទិន្នន័យពាក់ព័ន្ធបានឱ្យដឹងថា ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនោះ ផលិតផលសរុបនៅខេត្តយូនណានបានសម្រេចកំណើនប្រចាំឆ្នាំជាមធ្យម ៨,៩ភាគរយ ។ ទន្ទឹមនឹងនេះ អត្រាអាកាសធាតុល្អនៃក្រុងសំខាន់ៗក្នុងខេត្តយូនណាន មានកម្រិតលើសពី ៩៨ ភាគរយ ការផលិតអគ្គិសនីដោយប្រើថាមពលស្អាតមានចំនួនជាង៨០,៥ ភាគរយ ចំណែកបរិមាណនៃការចំណាយថាមពលធ្យេបនឹង GDP បានធ្លាក់ចុះ ២៣ភាគរយ ។ ជាពិសេសខេត្តយូនណានបានបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដើម្បីជំរុញការអភិវឌ្ឍថាមពលស្អាតនិងការសម្អាតទឹកកខ្វក់ ។ នៅឆ្នាំក្រោយ សន្និសីទលើកទី ១៥ នៃប្រទេសដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីជីវចម្រុះនៃអង្គការសហប្រជាជាតិនឹងត្រូវរៀបចំនៅខេត្តយូនណាន ។

លោក មូ ឃួយឡាន បានបន្តទៀតថា តំបន់ពិសោធន៍ពាណិជ្ជកម្មសេរីចិន(ខេត្តយូនណាន) ដែលទើបត្រូវសម្ពោធស្វាគមន៍ជាផ្លូវការនោះ នឹងអាចជំរុញបន្ថែមទៀតនូវការអភិវឌ្ឍន៍ដោយចីរភាពនៃខេត្តយូនណាន ។ ខេត្តយូនណានជាច្រកដ៏សំខាន់ដែលប្រទេសចិនបើកទូលាយចំពោះប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ខ្ញុំជឿជាក់ថា ការធ្វើពាណិជ្ជកម្មដោយមានភាពងាយស្រួលនឹងអាចដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ដោយចីរភាពនៃខេត្តយូនណាន ៕

(ការសែតយូនណាន ដេលី)

ឯកឧត្តម ស៊ុ ជីនភីងបកស្រាយពីគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ"

គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ស្របទៅនឹងនិន្នាការអភិវឌ្ឍន៍នៃយុគសម័យ ស្របទៅនឹងក្បួនច្បាប់នៃការអភិវឌ្ឍន៍ និងស្របទៅនឹងផលប្រយោជន៍រួមរបស់ប្រជាជននៃបណ្តាប្រទេសនានា ហើយនឹងអាចមានអនាគតដ៏ភ្លឺស្វាង ។ យើងត្រូវធ្វើដំណើរទៅមុខ និងខិតខំធ្វើការតាមនិន្នាការអភិវឌ្ឍន៍ ជំរុញការកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ"ដោយមានស្ថិរភាព ដើរឆ្ពោះទៅកាន់អនាគតកាន់តែភ្លឺស្វាង ។

(ដកស្រង់ចេញពីសុន្ទរកថាសំខាន់របស់ឯកឧត្តមស៊ុ ជីនភីង ដែលថ្លែងក្នុងពិធីបើកវេទិកាកំពូលស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" នៅថ្ងៃទី១៤ខែឧសភា ឆ្នាំ ២០១៧)

"ខ្សែក្រវាត់មួយនិងផ្លូវមួយ" បង្កើតកាលានុវត្តភាពនៃកិច្ចសហប្រតិបត្តិការ

លោក វិន គួស៊ុន ជាពាណិជ្ជករម្នាក់ដែលមកពីប្រទេសម៉ាឡេស៊ី ។ លោករកស៊ីនៅខេត្តយូនណានបាន ១១ ឆ្នាំហើយ ។ លោកបានបញ្ជាក់ថា ខេត្តយូនណានជាស្រុកកំណើតទី ២ របស់ខ្ញុំ ហើយក៏ជាទីដៅវិនិយោគល្អមួយសម្រាប់ពាណិជ្ជករបរទេស ។

លោកបានបញ្ជាក់ថា ខេត្តយូនណានជាប់ព្រំប្រទល់ជាមួយប្រទេសច្រើន ហើយមានឧត្តមភាពលើវិស័យទីតាំងភូមិសាស្ត្រ ដែលមិនអាចប្រៀបផ្ទឹមបាន ។ ក្នុងរយៈពេល ១១ ឆ្នាំកន្លងទៅនោះ ខ្ញុំបានធ្វើជាអ្នកសាក្សីនៃការរីកចម្រើនរបស់ខេត្តយូនណាន ។ ជាពិសេស ក្រោយពីគំនិតផ្តួចផ្តើម" ខ្សែក្រវាត់មួយ និងផ្លូវមួយ"ត្រូវបានលើកឡើងរៀងមកខេត្តយូនណានបានទទួលនូវការរីកចម្រើនកាន់តែអាប់រហ៊ស ហើយបាននាំមកនូវកាលានុវត្តភាព ថ្មីកាន់តែច្រើនដល់ប្រទេសអាស៊ី-អាគ្នេយ៍ និងអាស៊ីខាងត្បូងក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន។

ប៉ុន្មានឆ្នាំនេះ មិត្តភក្តិជាច្រើនរបស់លោកបានមកធ្វើវិនិយោគនៅខេត្តយូនណាន ។ លោកបានពង្រីកអាជីវ-ភាព របស់ខ្លួននៅខេត្តយូនណាន ។ លោកជឿជាក់ថា ក្រោមការជំរុញពីគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ទំនាក់ទំនងរវាងប្រទេសចិន នឹងប្រទេសអាស៊ីអាគ្នេយ៍អាស៊ីខាងត្បូងនឹងអាចត្រូវជំរុញនិងបង្កើនឱ្យកាន់តែស៊ីជម្រៅថែមទៀត ៕

លោកហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីកម្ពុជា: សមិទ្ធផលអភិវឌ្ឍន៍នៃប្រទេសចិនទទួលការចាប់អារម្មណ៍ពីពិភពលោក និងផ្តល់ផលប្រយោជន៍ដល់ពិភពលោក

ពេលថ្មីៗនេះ លោក ហោ-ណាំហុង ឧបនាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់បទសម្ភាសន៍ពិសេសជាមួយអ្នកកាសែតនៅរាជធានីភ្នំពេញថា ឆ្នាំ ២០១៩ ជាខួបលើកទី៧០ នៃការបង្កើតប្រទេសចិនថ្មី ។ ក្នុងរយៈពេល៧០ ឆ្នាំកន្លងទៅនោះ ប្រទេសចិនបានទទួលនូវការរីកចម្រើនច្រើនគួរឱ្យកត់សម្គាល់ ចំណែកជីវភាពរស់នៅរបស់ប្រជាជនចិនបានត្រូវលើកកម្ពស់ឥតឈប់ឈរ ។ ទន្ទឹមនឹងនេះ សមិទ្ធផលនៃការអភិវឌ្ឍរបស់ប្រទេសចិនបានផ្តល់ផលប្រយោជន៍ដល់ពិភពលោកទាំងមូល ។ ជាពិសេស គំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" នឹងអាចជំរុញការតភ្ជាប់គ្នា និងការអភិវឌ្ឍរួមនៃពិភពលោក ។

លោកបានមានប្រសាសន៍ថា តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ដែលរួមគ្នាបង្កើតដោយសហគ្រាសចិន និងកម្ពុជាមិនគ្រាន់តែបាននាំមកនូវគម្រោងទុនវិនិយោគ និងបច្ចេកទេសចិនដល់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានផ្តល់ដល់កម្ពុជានូវទស្សនៈអភិវឌ្ឍន៍សេដ្ឋកិច្ច និងបទពិសោធន៍របស់ប្រទេសចិនទៀតផង ។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុជាគំរូនៃតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា ។ ក្រុមហ៊ុនចំនួនជាង១៦០ ដែលចូលធ្វើអាជីវកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ បានផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរជាង ២ ម៉ឺននាក់ ។ ជាពិសេសតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសច្រើនដល់កម្មករខ្មែរ ។

ប្រទេសចិនជាដៃគូពាណិជ្ជកម្មធំជាងគេ និងជាប្រភពវិនិយោគធំបំផុតរបស់កម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំជាប់ៗគ្នា ។ ឯកឧត្តមបានបញ្ជាក់ថា ប៉ុន្មានឆ្នាំមកនេះ ប្រទេសកម្ពុជា និងចិនបានទទួលលទ្ធផលជាផ្លែផ្កាក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា ដោយសារគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" និងយុទ្ធសាស្ត្រចតុកោណស៊ីសង្វាក់គ្នាកម្រិតខ្ពស់ ដែលបានជំរុញឱ្យប្រទេសទាំងពីរទទួលបាននូវការរីកចម្រើនកាន់តែច្រើនឡើងៗក្នុងការធ្វើកិច្ចសហប្រតិបត្តិការលើវិស័យថាមពល គមនាគមន៍ និងការបណ្តុះបណ្តាលធនធានមនុស្សជាដើម ។

លោកបានលើកមតិថា ប្រទេសដែលចូលរួមការកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" អាចបង្កើនទំនាក់ទំនងតាមរយៈការសម្របសម្រួលក្នុងតំបន់ និងការអភិវឌ្ឍទាំងលើដីគោកនិងសមុទ្រជំរុញនិងសម្រេចនូវការអភិវឌ្ឍនិងវិបុលភាពរួម ៕

ដោយ ម៉ៅ ភឹងហ្វី (ស៊ីនហួ ចិន)

កម្មវិធី App "ដើរលេងខេត្តយូនណាន" ជាភាសាអង់គ្លេសត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

នៅថ្ងៃទី៤ ខែកញ្ញាឆ្នាំ២០១៩កម្មវិធី App"ដើរលេងខេត្តយូនណាន"ជាភាសាអង់គ្លេសត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងកិច្ចប្រជុំកំពូលប្រចាំឆ្នាំ ២០១៩ អំពីទេសចរណ៍ភ្នំក្រអូប ក្រុង Helsinki នៃសមាគមទីក្រុងទេសចរណ៍ពិភពលោក។

កម្មវិធី App "ដើរលេងខេត្តយូនណាន" ជាភាសាអង់គ្លេសមាន មុខងារដ៏ច្រើនដូចជា ការផ្សាយផ្ទាល់អនឡាញ ខ្សែផ្លូវទេសចរណ៍ល្អទិសដៅទេសចរណ៍ ការស្វែងរកជំនួយ និងការបកប្រែភាសាបរទេសជាដើម ដើម្បី ផ្តល់សេវាកម្មពេញលក្ខណៈដល់ទេសចរអន្តរជាតិដែលមកដើរលេងនៅខេត្តយូនណាន ។

កិច្ចប្រជុំកំពូលអំពីទេសចរណ៍ភ្នំក្រអូបលើកទី៨នេះ បានរៀបចំក្រោមប្រធានបទ "ទេសចរណ៍វែឆ្ងាត : ផ្លូវច្នៃប្រឌិតថ្មី និងអភិវឌ្ឍន៍នៃទីក្រុង" ។ កិច្ចប្រជុំកំពូលនេះបានទាក់ទាញតំណាងជាង៥០០រូប ដែលមកពីទីក្រុងជិតមួយរយនៃប្រទេសចំនួន៥៦ ។ អង្គប្រជុំបានប្រកាសនូវ "របាយការណ៍ប្រចាំឆ្នាំ២០១៩ អំពីការអភិវឌ្ឍទីក្រុងទេសចរណ៍លើពិភពលោក" និង "របាយការណ៍អំពីទីក្រុងទេសចរណ៍វែឆ្ងាតលើពិភពលោក" ។ កម្មវិធី App "ដើរលេងខេត្តយូនណាន" ដែលជាតំណាងនៃប្រព័ន្ធទេសចរណ៍វែឆ្ងាតរបស់ប្រទេសចិន បានត្រូវដាក់បញ្ចូលក្នុង" របាយការណ៍អំពីទីក្រុងទេសចរណ៍វែឆ្ងាតលើពិភពលោក" ៕

ដោយ លី ៣ និង វ៉ាង ហួន

ប្រជាជនជនជាតិភាគតិចចូលរួមការប្រកួតកីឡាប្រពៃណី

ការប្រកួតកីឡាប្រពៃណីជនជាតិភាគតិចចិនលើកទី១១ បានបើកការប្រកួតនៅក្រុងជីងចូវនៃខេត្តហ៊ឺណាន នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ២០១៩ ។ កីឡាប្រពៃណីរបស់ជនជាតិភាគតិចមានប្រភពដើម និងវិវឌ្ឍន៍ពីសកម្មភាពបង្កបង្កើនផល និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ជនជាតិភាគតិច ។

ការប្រកួតកីឡានេះនឹងរៀបចំរយៈពេល ៩ ថ្ងៃ ។ កីឡាករកីឡាការិនី ៧០០៩ នាក់ ដែលមកពីខេត្តចំនួន ៣១ ក្រុមទាហានស្តាបនាតំបន់ស៊ីនជាំង កងទ័ពរំដោះជាតិប្រជាជនចិន និងគណៈប្រតិភូជនជាតិភាគតិចតំបន់តៃវ៉ាន់នឹងចូលរួមការប្រកួតកីឡាអំពីវិញ្ញាសាប្រកួតកីឡាចំនួន១៧ និងកម្មវិធីសម្តែងកីឡាចំនួន១៩៤ ៕